# បទពិសោធន៍នៃការអនុវត្តគម្រោងលើកកម្ពស់ជីវភាព សហគមន៍ព្រៃឈើ ភូមិត្បែងលិច ឃុំត្បែង ស្រុកបន្ទាយស្រី ខេត្តសៀមរាប

*ឧបត្ថម្ភដោយ: ឯកឧត្តម បណ្ឌិត ច័ន្ទ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

*រៀបរៀងដោយ: ការិយាល័យផ្សព្វផ្សាយ និងទំនាក់ទំនងសាធារណៈ*

ព្រៃឈើមានសារសំខាន់ដល់ជីវិតមនុស្ស សត្វលើផែនដីដូចជា ការជួយធ្វើនិយ័តកម្ម អាកាសធាតុ ជួយកាត់បន្ថយឥទ្ធិពល អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុដូចជា ទឹកជំនន់ ខ្យល់ព្យុះ និងការស្រូបយកឧស្ម័នកាបូនិកពីបរិយាកាស។ ទន្ទឹមនឹងនេះព្រៃឈើផ្តល់នូវសេវាកម្ម និងជួយគាំពារផ្នែកបរិស្ថានជាច្រើនទៀត ដូចជា ការការពារទីជម្រាល ទប់ស្កាត់ការហូរច្រោះដី ការធ្វើឲ្យប្រសើរឡើងនៃគុណភាពដី និងផ្តល់នូវផល អនុផលព្រៃឈើជាច្រើនអនេកដល់ប្រជាពលរដ្ឋ ជាពិសេសរួចចំណែកដល់ការកាត់បន្ថយភាពក្រីក្ររបស់សហគមន៍នៅជនបទ។

សហគមន៍ព្រៃឈើត្បែងលិច ស្ថិតនៅឃុំត្បែង ស្រុកបន្ទាយស្រី ខេត្តសៀមរាប ត្រូវបានជ្រើសរើសជាសហគមន៍ ដើម្បីទទួលការអនុវត្តគម្រោងលើកកម្ពស់ជីវភាពសហគមន៍ព្រៃឈើ ក្រោមគំនិតផ្តួចផ្តើម និងអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិត **ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ គោលដៅគន្លឹះជាយុទ្ធសាស្ត្រនៃការសាកល្បង អនុវត្តគម្រោងនេះដើម្បីកាត់បន្ថយសម្ពាធនៃការប្រើប្រាស់ព្រៃឈើនិងលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ។ លើសពីនេះ ការអនុវត្តប្រព័ន្ធកសិកម្មចម្រុះ គឺដើម្បីធានាដល់សន្តិសុខស្បៀង បង្កើនប្រាក់ចំណូល បង្កើនការងារ និងដើម្បីធ្វើឲ្យប្រសើរឡើង ដល់ជីវភាពរស់នៅរបស់សមាជិកសហគមន៍មូលដ្ឋាន។

ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពសំដៅធានាបានផលប្រយោជន៍សម្រាប់សង្គម ជាពិសេសជួយបង្កើនផលិតភាពក្នុងវិស័យកសិកម្ម ដើម្បីជួយលើកស្ទួយជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋានដែលជាទិសដៅគន្លឹះនៃការចូលរួមកាត់បន្ថយភាពក្រីក្រស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ឯកសារនេះ គឺជាលទ្ធផលនិងបទពិសោធន៍នៃការអនុវត្ត ប្រព័ន្ធកសិកម្មចម្រុះ ដើម្បីជាគំរូដល់ការអនុវត្តឲ្យបានទូលំទូលាយបន្ថែមទៀតសម្រាប់កសិករដទៃទៀត។

យើងខ្ញុំសង្ឃឹមថា ឯកសារនេះជាជំនួយស្មារតី និងបទពិសោធន៍សម្រាប់ចែករំលែកដល់ប្រជាជនមូលដ្ឋានក្នុងការអនុវត្តប្រព័ន្ធកសិកម្មចម្រុះឲ្យទទួលបានជោគជ័យនៅថ្ងៃអនាគត។

## ១‚សេចក្តីផ្តើម

សុវត្ថិភាពស្បៀង ប្រាក់ចំណូល អាហារូបត្ថម្ភ ការប្រើប្រាស់ថាមពល និងការចិញ្ចឹមជីវិតមានទំនាក់ទំនងទៅនឹងព្រៃឈើនិងធនធានធម្មជាតិ។ ព្រៃឈើជា ធនធានធម្មជាតិដ៏មានសារសំខាន់ក្នុងការគាំទ្រដល់សហគមន៍ជនបទក្នុងប្រទេសកម្ពុជាដូចជា អុស ទឹកឃ្មុំ ជ័រ ផ្តៅ ផ្សិត បន្លែ ផ្លែឈើព្រៃ និងផលិតផលផ្សេងៗទៀតបានគាំទ្រដល់សេដ្ឋកិច្ចគ្រួសារ។ ព្រៃឈើពុំគ្រាន់តែមានតម្លៃខាងសេដ្ឋកិច្ច និងសង្គមជាតិប៉ុណ្ណោះទេ ថែមទាំងមានតម្លៃខ្ពស់មិនអាចប៉ាន់ប្រមាណបានលើផ្នែកថែរក្សាការពារលំនឹងបរិស្ថានធម្មជាតិ ធ្វើឲ្យធាតុអាកាសមានភាពកាន់តែប្រសើរឡើង ធ្វើឲ្យខ្យល់បរិសុទ្ធរក្សាបាននូវនិយ័តភាពប្រភពទឹក ការពារទីជម្រាល និងជីវចម្រុះ ចូលរួមកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទៅបរិយាកាសនិងជួយទ្រទ្រង់ជីវភាពរស់នៅសម្រាប់ប្រជាពលរដ្ឋរាប់លាននាក់ដែលពឹងពាក់អាស្រ័យទៅលើផល អនុផលព្រៃឈើ ។




ផែនទីបង្ហាញទីតាំងព្រៃសហគមន៍

## ២. ស្ថានភាពទូទៅនៃសហគមន៍ព្រៃឈើ

ខេត្តសៀមរាបបានចាប់ផ្តើមរៀបចំបង្កើតជាសហគមនព្រៃឈើចាប់តាំងពីឆ្នាំ១៩៩៧ បច្ចុប្បន្នមានសហគមន៍ព្រៃឈើចំនួន ៣៧កន្លែង ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញប្រកាសទទួលស្គាល់តំបន់សក្តានុពលនាថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៧ មានផ្ទៃដីសរុបចំនួន ១៨.១២២ ហិកតា និងបានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍បានចំនួន ៣៥កន្លែង មានផ្ទៃដីសរុបចំនួន ១៧.២៣៧ ហិកតា។

## ៣. សហគមន៍ព្រៃឈើភូមិត្បែងលិច

### ៣.១ ប្រវត្តិព្រៃឈើ

ចាប់ពីឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៨០ ព្រៃឈើភាគច្រើនគ្របដណ្តប់ទៅដោយព្រៃស្រោង និងសម្បូរទៅដោយសត្វព្រៃគ្រប់ប្រភេទ។ ប៉ុន្តែចាប់ពីឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៩០ ក្នុងពេលដែលប្រទេសមានសង្គ្រាមស៊ីវិលក្រុមហ៊ុនថៃបានធ្វើអាជីវកម្មឈើបណ្តាលឲ្យព្រៃឈើរងការបំផ្លិចបំផ្លាញជាដំណំ។ ចាប់ពីឆ្នាំ១៩៩០ ដល់ឆ្នាំ២០០០ សង្គ្រាមស៊ីវិលត្រូវបានបញ្ចប់ ប្រជាពលរដ្ឋបានប្រកបរបរធ្វើកសិកម្មពនេចរ ជាហេតុធ្វើឲ្យព្រៃឈើរងការគំរាមកំហែងមួយកម្រិតបន្ថែមទៀត។ ចាប់ពីឆ្នាំ២០០០ មកដល់បច្ចុប្បន្នសហគមន៍ព្រៃឈើត្រូវបានបង្កើតឡើង។

### ៣.២ ស្ថានភាពទូទៅ

ភូមិត្បែងលិចស្ថិតនៅ ឃុំត្បែង ស្រុកបន្ទាយស្រី ខេត្តសៀមរាប។ភូមិត្បែងលិចស្ថិតនៅចម្ងាយប្រមាណ ៣៥ គីឡូម៉ែត្រពីខេត្តសៀមរាបមានប្រជាជនសរុបចំនួន ១៨៣គ្រួសារ ស្មើនឹង៨៣៨នាក់(ស្ត្រីចំនួន៤៣៨នាក់)។ ភូមិនេះបានរៀបចំបង្កើតសហគមន៍ព្រៃឈើនៅឆ្នាំ២០០០ ដាក់ឈ្មោះថាសហគមន៍ ព្រៃឈើព្រៃក្បាលទឹក ជាប្រភេទព្រៃស្រោងរេចរឹល ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រកាសទទួលស្គាល់តំបន់ សក្តានុពលនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៧ ហើយខណ្ឌរដ្ឋបាលព្រៃឈើសៀមរាបបានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍នៅថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ។

ប្រជាជនដែលជាសមាជិកសហគមន៍ព្រៃឈើភូមិ

ត្បែងលិចពឹងផ្អែកលើមុខរបរសិកម្មដូចជាធ្វើស្រែ ដាំឈើហូបផ្លែដាំដំណាំ បន្លែ ចិញ្ចឹមសត្វ ដែលភាគច្រើនប្រកបកសិកម្មតាមបែបយថាផល និងទទួលបានទិន្នផលទាប។ ភូមិត្បែងលិចមានផ្ទៃដីសរុប ១០៩៥ហិកតា ក្នុងនោះមានផ្ទៃដីសហគមន៍ព្រៃឈើ ២១០ហិកតា ផ្ទៃដីលំនៅដ្ឋាន ៣៥ហិកតា ផ្ទៃដីស្រែ ១១០ហិកតា ផ្ទៃដីចម្ការ ២៥ហិកតា ផ្ទៃដីស្រូវចម្ការ ១៥ហិកតា និងផ្ទៃដីព្រៃឈើរេចរឹល ចំនួន ៧០០ហិកតា ។

### ៣.៣ ការអភិវឌ្ឍសហគមន៍ព្រៃឈើ

ដោយផ្អែកលើការជួយឧបត្ថម្ភ នៃគម្រោងលើកកម្ពស់ជីវភាពសហគមន៍ព្រៃឈើរបស់ឯកឧត្តមបណ្ឌិត **ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ដើម្បីរួមចំណែកធ្វើឲ្យប្រសើរឡើងនូវកម្រិតជីវភាពរស់នៅប្រចាំថ្ងៃរបស់សហគមន៍ និងស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកាត់បន្ថយភាពក្រីក្រ សហគមន៍ព្រៃក្បាលទឹក ជាសហគមន៍ដែលមានសក្តានុពលក្នុងការជ្រើសរើសជាសហគមន៍ឈានមុខគេសម្រាប់សាកល្បងអនុវត្តគម្រោងប្រព័ន្ធកសិកម្មចម្រុះចាប់តាំងពីខែឧសភា ឆ្នាំ២០១១ រហូតដល់បច្ចុប្បន្ន។

គោលបំណងសំខាន់ៗនៃគម្រោងលើកកម្ពស់ជីវភាពសហគមន៍ព្រៃឈើគឺ :

- ដើម្បីពង្រឹងសមត្ថភាពសមាជិកសហគមន៍ទាំងអស់អំពី បច្ចេកទេសប្រពលវប្បកម្មដំណាំស្រូវ (ប.វ.ស) បច្ចេកទេសដាំដំណាំនិងប្រើប្រាស់ពូជស្រូវថ្មីៗដែលផ្តល់ទិន្នផលខ្ពស់
- ដើម្បីផ្តល់ នូវបច្ចេកទេសចិញ្ចឹមសត្វ ជ្រូក មាន់ និងត្រី សម្រាប់រកប្រាក់ចំណូលបន្ថែម
- ជំរុញកសិករឲ្យចេះសន្សំ និងប្រើប្រាស់ជីធម្មជាតិ (ការបង្កើតរោងជីកំប៉ុស្តិ៍ និងឡជីវឧស្ម័ន)សម្រាប់ដំណាំស្រូវ បន្លែ ដំណាំរួមផ្សំ និងដំណាំឈើហូបផ្លែ
- ជំរុញកសិករឲ្យចេះដាំដំណាំឆ្លាស់ ដើម្បីថែរក្សាទម្រង់ ដី និងជីជាតិដីឲ្យមានល្អ
- ជំរុញកសិករឲ្យចេះរៀបចំកសិដ្ឋានចម្រុះ ចេះធ្វើផែនការផលិតកម្មកសិកម្ម និងសម្រាប់ទីផ្សារ។

## ៤. សកម្មភាព និងបទពិសោធន៍នៃការអនុវត្តគម្រោងប្រព័ន្ធកសិកម្មចម្រុះ

### ៤.១ ដំណាំស្រូវ



*រូបគំរូនៃការអនុវត្តប្រព័ន្ធកសិកម្មចម្រុះ*

កសិករ៩៥ គ្រួសារ បានទទួលពូជស្រូវ ៩៥០ គីឡូក្រាម (រួមមានពូជ ស្រូវរាំងជ័យ ផ្ការំដេង ផ្ការំដួល ផ្កាចាន់សែនស ជលសារ និងសែនពិដោរ)ដើម្បីយកទៅដាំដុះលើផ្ទៃដីចំនួន ៥២ ហិកតា ក្នុងនោះការអនុវត្តស្រែប្រពលវប្បកម្មចំនួន ២០,៣០ ហិកតា។ នេះជាផ្នែកមួយនៃការអនុវត្តវិធានការគោលនយោបាយ កំណត់ប្រភេទស្រូវសំខាន់ៗក្នុងស្រុក និងជំរុញផលិតកម្មដំណាំស្រូវ ។

ជាលទ្ធផលជាក់ស្តែងអំពីអត្ថប្រយោជន៍ នៃការអនុវត្ត ប្រពលវប្បកម្មដំណាំស្រូវកសិករចំនួន១៥គ្រួសារបានចងក្រង ជាក្រុមផលិតពូជស្រូវទាំង ១០មុខ សម្រាប់លក់ជូនដល់កសិករ ទាំងក្នុង និងក្រៅតំបន់។

### ៤.២ ការដាំបន្លែ

ក្រោយពីរដូវច្រូតកាត់រួចកសិករទាំង៩៥គ្រួសារ អាចមានលទ្ធភាពគ្រប់ៗគ្នាក្នុងការទិញពូជបន្លែសម្រាប់ដាំដុះ ពីព្រោះពួកគាត់បានថវិកាពីការលក់បន្លែដែលពួកគាត់បានដាំនៅរដូវវស្សាកន្លងមក។ ក្រៅពីនេះ ពួកគាត់មានចំណេះដឹង និងលទ្ធភាពក្នុងការធ្វើរោងជីកំប៉ុស្តិ៍ដោយខ្លួនឯងគឺជាផ្នែកមួយនៃការសន្សំជីធម្មជាតិសម្រាប់អនុវត្តនេះប្រព័ន្ធកសិកម្មចម្រុះ។

### ៤.៣ ការចិញ្ចឹមសត្វ

កសិករចំនួន ៩០គ្រួសារទៀត បានទទួលពូជមាន់ចំនួន ២០០ក្បាល និងបច្ចេកទេសធ្វើទ្រុងថែទាំ និងចិញ្ចឹមខ្លួនឯងពីមន្ទីរកសិកម្ម ខេត្តសៀមរាប។ ចំពោះ

កសិករដទៃទៀតថ្វីត្បិតតែពួកគាត់ពុំបានទទួលពូជមាន់ខាងលើ ប៉ុន្តែពួកគាត់ក៏ទទួលបានបច្ចេកទេសដូចគ្នាដើម្បីយកទៅចិញ្ចឹមមាន់របស់គាត់ដែលមានស្រាប់តាមគ្រួសារនីមួយៗ។

គម្រោងក៏បានផ្ដល់កូនជ្រូកពូជចំនួន២២ក្បាល និង បច្ចេកទេសធ្វើទ្រុងថែទាំ និងចិញ្ចឹមខ្លួនឯងដល់ក្រុមកសិករ (ពី៨–១២នាក់/ក្រុម)។

## ៤.៤ ការចិញ្ចឹមត្រី

កសិករចំនួន៩គ្រួសារត្រូវបានជ្រើសរើសដើម្បីអនុវត្តការចិញ្ចឹមត្រីចម្រុះ។ បច្ចុប្បន្ននេះប្រាក់ចំណូលរបស់កសិករបានពីការចិញ្ចឹមត្រី ក្រៅពីហូបជាប្រចាំថ្ងៃគាត់អាចលក់ត្រីជាមធ្យមពី ៣០០.០០០ទៅ ៥០០.០០០ រៀលក្នុង ១ គ្រួសារទៀតផង។

## ៤.៥ ឡជីវឧស្ម័ន

កសិករបានទទួលឡជីវឧស្ម័នចំនួន ១៣គ្រួសារពីគម្រោង។ លទ្ធផលជាក់ស្ដែងកសិករចំណេញពេលវេលាកាត់បន្ថយការកាប់ព្រៃឈើ ធ្វើអុសដុតចម្អិនអាហារ និងបានកាកសំណល់ពីឡទៅដាក់ដាំ បន្លែ និងដាំស្រូវបន្ថែមទៀតជំរុញឲ្យដំណាំដុះលូតលាស់ល្អ។ លើសពីនេះសហគមន៍ព្រៃឈើភូមិត្បែងលិចឃុំត្បែងស្រុកបន្ទាយស្រីត្រូវបានជ្រើសរើសសម្រាប់អនុវត្តគម្រោងឡជីវឧស្ម័នរបស់ មូលនិធិគ្លីនតុន។ ក្នុងនោះឡជីវឧស្ម័នចំនួន ០៨ នឹងត្រូវសាងសង់សម្រាប់ផ្ដល់ជូនសមាជិកសហគមន៍ ០៨គ្រួសារ។ កិច្ចសន្យា សាងសង់ឡជីវឧស្ម័នត្រូវចុះហត្ថលេខាដោយខណ្ឌរដ្ឋបាលព្រៃឈើសៀមរាប និង



*ទិដ្ឋភាពការសាងសង់ឡជីវឧស្ម័ន (ដែលផ្ដល់ថាមពលអាចកាត់បន្ថយការប្រើប្រាស់ថាមពលពីព្រៃឈើ )*



*ការចម្អិនអាហារដោយប្រើថាមពលពីឡជីវឧស្ម័ន*

មន្ទីរកសិកម្មខេត្តសៀមរាប។ គម្រោងបានជ្រើស រើសសហគមន៍ព្រៃឈើភូមត្បែងលិចដោយផ្អែកលើគោលការណ៍ដូចខាងក្រោម

– សហគមន៍គំរូក្នុងការអនុវត្តកម្មវិធីសហគមន៍ព្រៃឈើ ជាតិរួមមានការរៀបចំចងក្រងក្រុមសហគមន៍ បោះឆ្នោតជ្រើស រើសគណៈកម្មការគ្រប់គ្រង រៀបចំបទបញ្ញាផ្ទៃក្នុង លក្ខន្តិកៈ រៀបចំផែនទីព្រៃសហគមន៍ ការកំណត់ព្រំប្រទល់ និងចុះកិច្ចព្រមព្រៀង ព្រៃសហគមន៍

– ប្រជាពលរដ្ឋជាសមាជិកសហគមន៍មានការយល់ដឹងពីអត្ថប្រយោជន៍នៃព្រៃឈើ និងចូលរួមយ៉ាងសកម្មក្នុងការគ្រប់គ្រង និងអភិវឌ្ឍព្រៃសហគមន៍ទស្សនៈកិច្ចរបស់ភ្ញៀវជាតិ អន្តរជាតិ និងនិស្សិតជាតិ អន្តរជាតិ តែងតែចុះសិក្សាស្វែងយល់ ពីការអនុវត្តសហគមន៍ព្រៃឈើ

– ប្រជាពលរដ្ឋឧស្សហ៍ព្យាយាម មានចិញ្ចឹមសត្វពាហនៈ សម្រាប់ដំណើរការគម្រោងឡជីវឧស្ម័ន

– ប្រជាពលរដ្ឋមានធនធាននៅមូលដ្ឋានគ្រប់គ្រាន់ សម្រាប់រៀបចំបង្កើតរោងជីកំប៉ុស្ត ដោយប្រើប្រាស់ធនធានផល អនុផលព្រៃឈើពីព្រៃសហគមន៍

– ប្រជាពលរដ្ឋឧស្សាហ៍ព្យាយាមក្នុងការដាំបន្លែបង្កា ដោយអាចប្រើប្រាស់កាកសំណល់ពីឡជីវឧស្ម័នសម្រាប់ដាំដុះដំណាំ

– គ្រួសារមានផ្ទៃដីលំនៅស្ថានសមស្របសម្រាប់រៀបចំបង្កើតរោងជីកំប៉ុស្តឡជីវឧស្ម័ន និងផ្ទៃដីដាំដំណាំគ្រប់ប្រភេទ

– មានទីតាំងភូមិសមស្របសម្រាប់បង្ហាញអត្ថ



*ចង្កៀងដែលប្រើដោយថាមពលពីឡជីវឧស្ម័ន*

ប្រយោជន៍ឡជីវឧស្ម័នដល់ប្រជាពលរដ្ឋនៅភូមិដទៃៗទៀត។

## ៤.៦ ការចិញ្ចឹមឃ្មុំ

អ្នកភូមិត្បែងលិចស្ទើរតែទាំងអស់មានប្រពៃណីចិញ្ចឹមឃ្មុំតាំងពីឆ្នាំ១៩៧៣ មកម្ល៉េះ។ បច្ចុប្បន្នដោយសារធនធានព្រៃឈើរងការបំផ្លិចបំផ្លាញ ធ្វើឲ្យការចិញ្ចឹមឃ្មុំជាលក្ខណៈធម្មជាតិ របស់អ្នកភូមិថយចុះមកត្រឹមតែ៣០គ្រួសារប៉ុណ្ណោះ។ ក្នុងមួយគ្រួសារគេដាក់បង្គងពី១៥០ទៅ ២០០ បង្គង ដែលបង្គងនីមួយៗមានប្រវែង២.៥០ម៉ែត្រ ដែលមានមុខកាត់ពី ៨-១០ សង់ទីម៉ែត្រ ដោយជ្រើសរើសប្រភេទឈើដែលឃ្មុំចូលចិត្តរស់នៅរួមមានកកោះ ត្រសេក ផ្ដៀង យាងបោង ពពេល និងច្រម៉ាស់។ ការដាក់បង្គងត្រូវការទ្រនល់ពីរដើមដែលមានប្រវែង២.៥០ ម៉ែត្រ និង១.៥០ម៉ែត្រ ដោយពុំចាំបាច់ជ្រើសរើសប្រភេទឈើឡើយ។ បង្គងដាក់ចម្ងាយពីព្រៃសហគមន៍ប្រមាណ ៥០០ ម៉ែត្រ ដែលដាក់នៅទីតាំងព្រៃគុម្ពោតកម្ពស់ជាមធ្យមប្រមាណ ៣-៤ម៉ែត្រ ។ ពេលដែលឃ្មុំទំលើបង្គងណាមួយ បង្គងនោះអាចប្រើប្រាស់បានរយៈពេលពី ២-៣ ឆ្នាំដោយពុំចាំបាច់ប្ដូរបង្គងថ្មីឡើយ។ ក្នុងផ្ទៃដីមួយហិកតា អាចដាក់បង្គងបានប្រមាណពី១០-១៥ បង្គង និងចន្លោះពីបង្គងមួយទៅបង្គងមួយទៀតពី៣០-៥០ ម៉ែត្រ។

អ្នកភូមិតែងដាក់បង្គងដើមខែតុលា និងប្រមូលផលពីខែកុម្ភៈ ដល់ ខែមេសា។ រយៈពេលមួយសប្ដាហ៍ក្រោយពីការដាក់បង្គង ឃ្មុំអាចទំនៅ ប៉ុន្ដែមានករណីខ្លះរហូតដល់ ២-៣ ខែ ទើបទំនៅ។ ក្នុងបង្គងមួយអាចប្រមូលទឹកឃ្មុំពី ៥-១២ លីត្រ។ជាទូទៅភូមិនេះអាចប្រមូលទឹកឃ្មុំជាមធ្យមចំនួនពី៥០០-៨០០លីត្រក្នុងមួយឆ្នាំ។

អ្នកភូមិបានដឹកទឹកឃ្មុំទៅលក់ផ្ទាល់នៅសណ្ឋាគារលំដាប់ផ្កាយប្រាំក្នុងក្រុងសៀមរាបដែលមានតំលៃ ១០ ដុល្លារ ក្នុងមួយលីត្រដោយពុំមានការវិចខ្ចប់បានត្រឹមត្រូវទេ។ ចំណែកក្រមួនឃ្មុំវិញត្រូវបានលក់ទៅកាន់វត្តអារ៉ាមនៅជិតភូមិដែលមានតម្លៃ ៥ម៉ឺនរៀលក្នុងមួយគីឡូក្រាម។



*ការចិញ្ចឹមឃ្មុំក្នុងព្រៃសហគមន៍*



## ៥.លទ្ធផលសម្រេចបានរបស់គម្រោង

បានរៀបចំចងក្រងក្រុមកសិករចំនួន១១ក្រុម (មួយក្រុម ពី ៨ ទៅ ១២ នាក់ ) និងជំរុញកសិករមកបិទភ្លឺស្រែ រៀបចំដី និងធ្វើថ្នាលសំណាបឲ្យបានទាន់ពេលវេលាដាំដុះ ។ បានបណ្ដុះបណ្ដាលកសិករធ្វើស្រែបច្ចេកទេសប្រពលវប្បកម្មដំណាំស្រូវ (ប.វ.ស) និងផ្សព្វផ្សាយឯកសារ ប.វ.ស ដល់កសិករក្នុងភូមិ ។ ជាមួយគ្នានោះបានបណ្ដុះបណ្ដាលដល់កសិករក្នុងការ

ចិញ្ចឹមត្រីក្នុង ស្រះ និងបានជ្រើសរើសកសិករធ្វើការបង្ហាញសម្រាប់ធ្វើប្រព័ន្ធកសិកម្មចម្រុះ និងអនុវត្តធ្វើស្រែតាមរយៈ ប.រ.ស។ បានចែកពូជស្រូវចំនួន ៩៥០ គីឡូក្រាមដល់សមាជិកសហគមន៍ចំនួន ៩៥ គ្រួសារ (ពូជផ្កាំរំដួល ផ្កាំរំដេង ផ្កាចាន់សែនស ពូជសែនពិដោរ ពូជរាំងជ័យ និង ពូជជលសារ )។

ខណ្ឌរដ្ឋបាលព្រៃឈើសៀមរាបបានផ្តល់ឡជីវឧស្ម័នចំនួន ០៣គ្រួសារ ។ ផ្តល់ពូជជ្រូកចំនួន ២២ ក្បាលជូនកសិករ១១ ក្រុម (មួយក្រុមពី៨ ទៅ ១២នាក់) ផ្តល់ពូជមាន់ចំនួន២៣០ក្បាល ដល់កសិករ ៤០ គ្រួសារ ផ្តល់ឧបករណ៍សំអាតស្មៅ ៦គ្រឿង ផ្តល់ទុយោទឹក ប្រវែង ៧០ម៉ែត្រ ដែលមានមុខកាត់ ៧២សង់ទីម៉ែត្រ ជូនដល់កសិករឈ្មោះ តាសណ្តែក។ កសិករចំនួន ៥៩គ្រួសារ បានរៀបចំធ្វើរោងជីកំប៉ុស្ត និងបានរៀបចំសាកល្បងចិញ្ចឹមជន្លេន ក្នុងលូស៊ីម៉ង់ចំនួន ០៤កន្លែង។

ម្យ៉ាងទៀតការអនុវត្តគម្រោងលើកកម្ពស់ជីវភាពសហគមន៍ព្រៃឈើក៏បានធ្វើឲ្យជីវភាពប្រជាជនមានភាពប្រសើរឡើងដូចជា បានធ្វើឲ្យមានការកើនឡើងនូវបរិមាណទឹកជប់ ដែលមានប្រភពមកពីតំបន់ព្រៃសហគមន៍ ដែលអាចឲ្យប្រជាពលរដ្ឋបានបង្កបង្កើនផល និងបន្តអនុវត្តប្រព័ន្ធកសិកម្មចម្រុះប្រកបដោយចីរភាព ព្រមទាំងជាកត្តាលើកទឹកចិត្តដល់សហគមន៍ក្នុងការគ្រប់គ្រងព្រៃសហគមន៍បានល្អប្រសើរឡើងក្នុងការកាត់បន្ថយបាននូវការកាប់បំផ្លាញព្រៃឈើ និងការប្រើប្រាស់ថាមពលអុសសម្រាប់ចម្អិនអាហារ។

## ៦.កិច្ចសហការ និងការចូលរួមរបស់ស្ថាប័នពាក់ព័ន្ធ

កត្តាជោគជ័យនៃការអនុវត្តគម្រោងលើកកម្ពស់ជីវភាពសហគមន៍ព្រៃឈើគឺដោយសារការពង្រឹងស្ថាប័ន និងមានកិច្ចសហការជិតស្និទ្ធរវាងអង្គភាពនានាក្រោមចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមមាន ខណ្ឌរដ្ឋបាលព្រៃឈើសៀមរាប មន្ទីរកសិកម្មខេត្ត ខណ្ឌរដ្ឋបាលជលផល និងការិយាល័យផលិតកម្មបសុព្យាបាលក្នុងការផ្តល់សេវាកម្មលើការបណ្តុះបណ្តាលបច្ចេកទេស និងផ្តល់មធ្យោបាយសម្ភារៈព្រមទាំងអន្តរាគមន៍នានាពេលកសិករជួបប្រទះនូវបញ្ហាប្រឈមនានា អង្គភាពនានាក្រោមចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទក៏បានរៀនសូត្រស្វែងយល់ពីស្ថានភាពបង្កបង្កើនផល ការគ្រប់គ្រងព្រៃឈើរបស់ប្រជាពលរដ្ឋមូលដ្ឋានព្រមទាំងអាចដោះស្រាយបញ្ហាប្រឈមបច្ចេកទេសផ្សេងៗជូនកសិករបានទាន់ពេលវេលា។

## ៧. សេចក្តីសន្និដ្ឋាន

ការអនុវត្តគម្រោងលើកកម្ពស់ជីវភាពសហគមន៍ព្រៃឈើ ភូមិត្បែងលិច ឃុំត្បែង ស្រុកបន្ទាយស្រី ពិតជាបានធ្វើឲ្យជីវភាពកសិករមានភាពប្រសើរឡើងតាមរយៈមុខរបរកសិកម្មចម្រុះទៅតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិត **ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលបានផ្តួចផ្តើមអនុវត្ត និងឧបត្ថម្ភគម្រោងនេះរហូតដល់បច្ចុប្បន្ន។ តាមរយៈការយល់ដឹងលើបច្ចេកទេសកសិកម្មចម្រុះរបស់សមាជិកសហគមន៍ បានជំរុញឲ្យជីវភាពរបស់កសិករមានភាពរីកចម្រើនជាបន្តបន្ទាប់ និងឈានទៅដល់ការពង្រីកប្រព័ន្ធកសិកម្មចម្រុះដល់កសិករក្នុងនិងក្រៅតំបន់គោលដៅ ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ ប្រជាពលរដ្ឋ។

ការអនុវត្តគម្រោងនេះជំរុញឲ្យមានការពង្រឹងស្ថាប័ន និង មានកិច្ចសហការជិតស្និទ្ធបំពេញការងាររួមគ្នារវាងអង្គភាពនានាក្រោមចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរួមមាន ខណ្ឌរដ្ឋបាលព្រៃឈើសៀមរាប មន្ទីរកសិកម្មខេត្ត ខណ្ឌរដ្ឋបាល ជលផល និងការិយាល័យផលិតកម្មបសុព្យាបាល ក្នុងការផ្តល់សេវាកម្មលើការបណ្តុះបណ្តាលបច្ចេកទេស និងផ្តល់មធ្យោបាយ សម្ភារៈព្រមទាំងអន្តរាគមន៍នានាពេលកសិករជួបប្រទះនូវបញ្ហាប្រឈមនានា។ លើសពីនេះ ការអនុវត្តគម្រោងនេះបានជួយដល់ការអនុវត្តការគ្រប់គ្រងព្រៃឈើនៅមូលដ្ឋានឲ្យទទួលបានជោគជ័យ និងគង់វង្សទៅថ្ងៃអនាគត។